## មន្ទីរកសិកម្មខេត្តកណ្តាល


# ល្ហុង




**អាស័យដ្ឋានទំនាក់ទំនង: ផ្លូវលេខ ១០៣ (តាខ្មៅ)**

**ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)**

**(០១២ ៨២៤ ៤២៥)**


---


**ឧបត្ថម្ភដោយ: អង្គការវីវីអូប៊ី VVOB**

**ឆ្នាំ ២០១០**


# ដំណាំល្ហុង

## ១- សេចក្តីផ្តើម

ល្ហុងជាដំណាំមួយប្រភេទ ដែលមានសារៈសំខាន់ចំពោះមនុស្ស និងសត្វ។ វាជាប្រភពមួយផ្តល់នូវជីវជាតិផ្សេងៗគ្នា ដូចជាអង្គធាតុរ៉ែ សាធាតុសរីរាង្គ វីតាមីនអា និងវីតាមីនសេ ដែលមានប្រយោជន៍ចាំបាច់សំរាប់មនុស្ស។ ការបរិភោគផ្លែល្ហុងទុំអាចជួយក្នុងការរំលាយអាហារ។ នៅប្រទេសកម្ពុជាយើង ដំណាំល្ហុងត្រូវបានគេដាំតាំងពីយូរយារណាស់មកហើយ តែគេដាំសំរាប់ផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសារ និងសល់ពីការហូបចុកខ្លះគេអាចយកទៅលក់នៅទីផ្សារ។ ផ្លែល្ហុងខ្ចីគេអាចយកទៅធ្វើជាបន្លែសំរាប់ស្ល ជ្រក់ ស្ងោរស៊ុប។ល។

**សារៈប្រយោជន៍នៃដំណាំល្ហុងៈ**

ក្នុងជីវភាពរស់នៅ គេអាចយកផ្លែល្ហុងមកប្រើប្រាស់បានច្រើនយ៉ាង ដោយវាសំបូរទៅដោយវីតាមីនជាច្រើនហើយក៏ជាអាហារដ៏ប្រសើរសំរាប់មនុស្សពេញវ័យ និងកុមារ។ ផ្លែល្ហុង គេអាចយកមកប្រើប្រាស់បាន ២យ៉ាង គឺសំរាប់ហូបជាអាហារស្រស់ និងជាផលិតផលកែច្នៃ ។

ប្រើសំរាប់ជាអាហារស្រស់ គឺគេបរិភោគផ្លែស្រស់ និងសំរាប់ហូបជាបន្លែផ្សេងទៀត ដូចជា ស្ល ជ្រក់ ស្ងោរ......

ប្រើសំរាប់ជាផលិតផលកែច្នៃ គឺទាំងផ្លែនៅខ្ចី និងទុំគេអាចយកទៅធ្វើជាអាហារកំប៉ុង ស្រា ទឹកផ្លែឈើ ដំណាប់.....

ផ្លែទុំគេអាចយកធ្វើជាថ្នាំសំរាប់ព្យាបាលជម្ងឺក្រពះ ឯផ្លែខ្ចីវិញគេអាចយកជ័រដែលមានជាតិប៉ាប៉ែនសំរាប់ជួយដល់ដំណើរឈាមរត់នៅក្នុងខ្លួនរបស់យើង និងជួយដល់សាច់ដុំ ធ្វើថ្នាំដុសធ្មេញ ថ្នាំសំរាប់សំអាតស្បែក និងម្សៅលាបមុខ។ ចំណែកឯស្លឹក គេអាចយកធ្វើថ្នាំសំរាប់ព្យាលបាលជម្ងឺហើមស្លឹក និងឫសធ្វើថ្នាំព្យាលបាលសរសៃប្រសាទ គ្រាប់វាចំរាញ់ធ្វើប្រេង ។

## ២- ពូជ

នៅក្នុងប្រទេសកម្ពុជាយើង ពូជល្ហុងមានពីរប្រភេទគឺ ពូជល្ហុងលក្ខ័ និង ពូជល្ហុងដំឡូង ឬ ល្ហុងពងមាន់ ។

**ពូជល្ហុងលក្ខ័ៈ**

ពូជល្ហុងប្រភេទនេះ គេនិយមចូលចិត្តដាំជាងពូជល្ហុងដំឡូង ឬ ល្ហុងពងមាន់ព្រោះវាមានឱជារសឆ្ងាញ់ពិសា។ ពូជល្ហុងប្រភេទនេះមានដើមពណ៌ស្វាយរហូតដល់ធាង។ ផ្លែវាមានពណ៌បៃតងខ្ចី ផ្លែរាងទ្រវែង មានគ្រាប់តិចនៅពេលទុំមានសំបកពណ៌លឿង និងសាច់ក្រហម។

**ពូជល្ហុងដំឡូង ឬល្ហុងពងមាន់ៈ**

ពូជល្ហុងប្រភេទនេះ គេពុំសូវនិយមចូលចិត្តដាំប៉ុន្មានទេ ព្រោះវាពុំសូវមានរសជាតិផ្អែមឆ្ងាញ់ពិសា ប៉ុន្តែវាងាយស្រួលក្នុងការដាំដុះជាងពូជល្ហុងលក្ខ័។ ដើម និងផ្លែមានពណ៌បៃតង ពេលទុំមានពណ៌លឿង ពុំសូវផ្អែមហើយមានគ្រាប់ច្រើន។

## ៣. វិធីសាស្ត្រក្នុងការដាំដុះ

**លក្ខខណ្ឌដីៈ** ដំណាំល្ហុងត្រូវការដីមានសភាពធូរហើយស្រស់ទឹក និងសំបូរទៅដោយជីវជាតិ ជាពិសេសគឺដីកណ្តៀង ឬដីល្បាយខ្សាច់។